ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(គ.ជ.អ.ប.)

# ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨

ខែមីនា ឆ្នាំ២០១៨

# អារម្ភកថា

ចក្ខុវិស័យនៃផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺ រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានកាន់តែប្រសើរ សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ចាំបាច់ត្រូវផ្តល់នូវស្វ័យភាពបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានមុខងារ ធនធានមនុស្សដែលមានសមត្ថភាព និងធនធានហិរញ្ញវត្ថុសមស្របក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជននានា។ ក្នុងការអនុវត្ត កិច្ចការ ទាំងនេះទាមទារនូវការចូលរួម និងការប្តេជ្ញាចិត្តខ្ពស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរយៈពេលមួយសមស្រប ដើម្បីធានាថា រដ្ឋបាលមូលដ្ឋាន ជាពិសេសរដ្ឋបាល ក្រុង ស្រុក ក្លាយជាអ្នកផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដោយផ្ទាល់ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។

ក្នុងអំឡុងពេលនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៧ យើងសម្រេចបាននូវលទ្ធផលសំខាន់ៗជាច្រើនដូចជា លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធកសាង ការបង្កើតនិងកិច្ចដំណើរការនៃយន្តការច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ និងផែនការអនុវត្តបីឆ្នាំដំណាក់កាលទី៣នៃកម្មវិធីជាតិត្រូវបានអនុម័តដោយ គ.ជ.អ.ប.។ ពាក់ព័ន្ធនឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ផែនការសកម្មភាពរួមគ្នាស្តីពីការងារគណនេយ្យភាពសង្គមចំនួនជាង៥៥០ត្រូវបានរៀបចំ ដោយអ្នកចូលរួមប្រមាណជាង១៦.០០០នាក់។ ចំពោះការងារគ្រប់គ្រងធនធានមនុស្ស យើងបានរៀបចំបញ្ចប់នូវបែបបទ និងនីតិវិធីវិធីស្តីពីការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពសរុបចំនួនជាង៦០០វគ្គ ត្រូវបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់មន្ត្រីរាជការសរុបចំនួនជាង៤២.០០០នាក់ក្នុងនោះមានស្ត្រីចំនួនប្រមាណ១០.០០០នាក់។ នៅខែឧសភា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីការរៀបចំផ្ទេរមុខងារចំនួន២៨ពីក្រសួង ស្ថាប័នក្នុងវិស័យជាអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលក៏បានអនុម័ត និងដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសហគមន៍ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាមួយនឹងលទ្ធផលខាងលើ យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបន្តអនុវត្ត តាមរយៈ ផ.ស.ថ. ឆ្នាំ២០១៨។ ផ.ស.ថ. ឆ្នាំ ២០១៨ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពជាច្រើនត្រូវសម្រេច ដែលក្នុងនោះលទ្ធផលរំពឹងទុកមួយចំនួនធំជាកិច្ចការ ដែលត្រូវបន្តអនុវត្តពីឆ្នាំ២០១៧ និងកិច្ចការថ្មីៗមួយចំនួនទៀតដែលបានកំណត់ក្នុងផអ៣ទី៣សម្រាប់ឆ្នាំ២០១៨។ ជារួម កិច្ចការសំខាន់ៗដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៨ រួមមានដូចខាងក្រោម ៖

**ទីមួយ** ៖ ការធានាភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដឹកនាំ សម្របសម្រួល រៀបចំ និងអនុវត្តកិច្ចដំណើរការកំណែទម្រង់។ ភាពមិនច្បាស់លាស់របស់ដៃគូអភិវឌ្ឍក្នុងការបន្តគាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានធ្វើឱ្យការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨មានភាពរអាក់រអួល និងយឺតយ៉ាវជាខ្លាំង។ អាស្រ័យហេតុនេះ យើងត្រូវធានាថា ចាប់ពីឆ្នាំ២០១៩តទៅ សកម្មភាពនានានៃការងារកំណែទម្រង់ត្រូវតែទទួលខុសត្រូវដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវបានដាក់បញ្ចូលសកម្មភាពទាំងនោះទៅក្នុងផែនការ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របតាមសេចក្តីណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧។ ជាមួយគ្នានេះដែរ យើងត្រូវខិតខំរៀបចំឱ្យបានចប់សព្វគ្រប់នូវឯកសារនានា ដើម្បីធានាថា លេខាធិការដ្ឋាន គ.ជ.អ.ប. ក្លាយជាអង្គភាពថវិកានៅឆ្នាំ២០១៩។

**ទីពីរ** ៖ ការធានាបាននូវការគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយរដ្ឋបាលក្រុង ស្រុកនូវមុខងារដែលបានផ្ទេរ។ ក្នុងអំឡុង ឆ្នាំ ២០១៦ និងឆ្នាំ២០១៧ មុខងារមួយចំនួនដូចជា មុខងារក្នុងវិស័យអប់រំ បរិស្ថាន អភិវឌ្ឍជនបទ និងសង្គមកិច្ចត្រូវ បានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ប៉ុន្តែមុខងារទាំងនេះពុំបានអនុវត្ត ឬចាប់ផ្តើមអនុវត្តដោយរលូននៅឡើយទេ។ អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១៨ យើងត្រូវធានាថា មុខងារទាំងនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យបានច្បាស់លាស់នូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ ផែនការសកម្មភាពនិងថវិកាសម្រាប់ការអនុវត្តលិខិតបទដ្ឋាន និងសេចក្តីណែនាំទាំងនោះ និងការពង្រឹងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបានការផ្ទេរមុខងារក្នុងបែបផែនជាគម្រោង។ ចំពោះក្រសួង ស្ថាប័នផ្សេងទៀត ត្រូវផ្តោតលើការសិក្សា និងវិភាគជាមុនឱ្យបានច្បាស់លាស់អំពីមុខងារ និងធនធាននានាដែលត្រូវផ្ទេរ មុននឹងឈានទៅដល់ការផ្ទេរមុខងារជាក់ស្តែង។

**ទីបី** ៖ ការពង្រឹងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ កន្លងមក ការអភិវឌ្ឍសមត្ថភាពផ្តោតជាសំខាន់លើសមត្ថភាពក្នុងការអនុវត្តលិខិតបទដ្ឋាន សេចក្តីណែនាំ ប្រព័ន្ធ និងនីតិវិធីនានាដែលបានដាក់ឱ្យអនុវត្តដោយថ្នាក់ជាតិ។ ប៉ុន្តែ នៅពេលដែលមុខងារត្រូវបានផ្ទេរជាបន្តបន្ទាប់ ការអភិវឌ្ឍសមត្ថភាពត្រូវផ្តោតលើចំណេះដឹង និងជំនាញជាក់ស្តែងក្នុងការអនុវត្តមុខងារទាំងនោះ។ អាស្រ័យហេតុ ត្រូវយកចិត្តទុកដាក់លើការពិនិត្យ និងការកែសម្រួលវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពកន្លងមករួមបញ្ចូលទាំងការកំណត់ស្តង់ដារ ការរៀបចំប្លង់មេរៀន និងវិធីសាស្ត្រផ្សេងៗនៃការអភិវឌ្ឍសមត្ថភាពដូចជា ការអភិវឌ្ឍសមត្ថភាពតាមតាមរយៈការដោះស្រាយបញ្ហាជាក់ស្តែង និងតាមរយៈការបង្ហាត់បង្ហាញជាដើម។ ជាមួយគ្នានេះដែរ ត្រូវពិនិត្យមើលឡើងវិញនូវ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ដើម្បីបែងចែងឱ្យបានច្បាស់នូវតួនាទីត្រួតពិនិត្យនិងផ្តល់ការគាំទ្រ និងតួនាទីក្នុងការផ្តល់សេវារបស់ថ្នាក់រដ្ឋបាលនីមួយៗ។

**ទីបួន** ៖ ការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន ស្ត្រីកាន់មុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្តមានចំនួន១២% និងថ្នាក់ក្រុង ស្រុក ខណ្ឌមានចំនួន២១%។ ក្នុងឆ្នាំ២០១៧ មន្ត្រីរដ្ឋបាលសាធារណៈជាស្ត្រីមួយរូប ត្រូវបានតែងតាំងជាអភិបាលខេត្តកោះកុងដែល

ជាមុខតំណែងគ្រប់គ្រងខ្ពស់បំផុតមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៨ កិច្ចការនេះត្រូវយកចិត្តទុកដាក់អនុវត្តបន្ត និងត្រូវសម្រេចឱ្យបានយ៉ាងតិច២០% សម្រាប់មុខតំណែងគ្រប់គ្រងថ្នាក់រាជធានី ខេត្ត និង២៥% សម្រាប់មុខតំណែងគ្រប់គ្រងថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ទីប្រាំ** ៖ ការបង្កើនធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ធនធានហិរញ្ញវត្ថុពិតជាមានសារៈសំខាន់សម្រាប់ការធ្វើវិមជ្ឈការ។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិពុំអាចអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ប្រសិនបើរដ្ឋបាលទាំងនោះពុំមានធនធានហិរញ្ញវត្ថុសមស្របនោះទេ។ អាស្រ័យហេតុនេះ ការបង្កើនធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការមួយដ៏មានសារៈសំខាន់ និងមិនអាចខ្វះបាន។ ដូច្នេះ កិច្ចការជាអាទិភាពដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ២០១៨ គឺការពិនិត្យមើលឡើងវិញ និងការកែសម្រួលរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកធនធានទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗប្រកបដោយសមធម៌ ការបង្កើននូវការចែករំលែកចំណូលពន្ធនិងមិនមែនសារពើពន្ធ និងការផ្តល់មូលនិធិបន្ថែម តាមរយៈមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ត្រូវពិនិត្យ និងកែសម្រួលឡើងវិញនូវនីតិវិធីសម្រាប់ការបែងចែក និងការចំណាយមូលនិធិផ្នែកអភិវឌ្ឍ និងមូលនិធិផ្នែករដ្ឋបាល ដើម្បីបង្កើនការវិនិយោគលើគម្រោងអភិវឌ្ឍមូលដ្ឋានទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។

ភាពជោគជ័យក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៨ អាស្រ័យលើកិច្ចខិតខំប្រឹងប្រែង ការប្រឹក្សាយោបល់ និងការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតទាំងអស់។ ជាមួយគ្នានេះដែរ ភាពជោគជ័យនៃការអនុវត្តផែនការនេះក៏អាស្រ័យទៅលើការសម្របសម្រួល និងកិច្ចសហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងកម្មវិធីកំណែទម្រង់ផ្សេងទៀតដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកំណែទម្រង់តាមវិស័យនានាផងដែរ។ កំណែទម្រង់ទាំងនេះ គឺជាកត្តាដ៏មានសារសំខាន់ ដើម្បីទទួលបានជោគជ័យក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងនាមរាជរដ្ឋាភិបាល គ.ជ.អ.ប. នឹងបន្តពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់ ក្នុងគោលបំណងផ្តល់ជាផលប្រយោជន៍យ៉ាងពិតប្រាកដជូនប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះនានា។

ថ្ងៃសុក្រ ៨ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា

**អារម្ភកថា** ............ i
**បញ្ជីតារាង** ............ vi
**បញ្ជីអក្សរកាត់** ............ vii
**I. សេចក្តីផ្តើម** ............ **១**
ក. លទ្ធផលរំពឹងទុកជាអាទិភាពឆ្នាំ២០១៨ ............ ២
ខ. គម្រោងចំណាយ និងប្រភពមូលនិធិឆ្នាំ២០១៨ ............ ៨
ខ.១. ផែនការចំណាយ ............ ៨
ខ.២. ប្រភពមូលនិធិ ............ ៩
**II. សមាសភាគនានានៃ គ.ស.ថ ឆ្នាំ២០១៨** ............ **១១**
***សមាសភាគទីមួយ ÷ ការគ្រប់គ្រងការងារកំណែទម្រង់*** ............ **១២**
ក. សេចក្តីផ្តើម ............ ១២
ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក ............ ១២
គ. សូចនាករ និងចំណុចដៅ ............ ១២
ឃ. លទ្ធផលរំពឹងទុក និងថវិកា ............ ១៣
***សមាសភាគទីពីរ ÷ អភិបាលកិច្ចល្អ*** ............ **១៥**
ក. សេចក្តីផ្តើម ............ ១៥
ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក ............ ១៥
គ. សូចនាករ និងចំណុចដៅ ............ ១៦
ឃ. លទ្ធផលរំពឹងទុក និងថវិកា ............ ១៦
***សមាសភាគទីបី ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស*** ............ **១៨**
ក. សេចក្តីផ្តើម ............ ១៨
ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក ............ ១៨
គ. សូចនាករ និងចំណុចដៅ ............ ១៨
ឃ. លទ្ធផលរំពឹងទុក និងថវិកា ............ ១៩
***សមាសភាគទីបួន ÷ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន*** ............ **២០**
ក. សេចក្តីផ្តើម ............ ២០
ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក ............ ២០
គ. សូចនាករ និងចំណុចដៅ ............ ២០
ឃ. លទ្ធផលរំពឹងទុក និងថវិកា ............ ២១

**សមាសភាគទី៣ ÷ វិមជ្ឈការហិរញ្ញវត្ថុ** ........ **២៤**
ក. សេចក្តីផ្តើម ........ ២៤
ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក ........ ២៤
គ. សូចនាករ និងចំណុចដៅ ........ ២៤
ឃ. លទ្ធផលរំពឹងទុក និងថវិកា ........ ២៥
III. **ការផ្ទេរធនធានហិរញ្ញវត្ថុឆ្នាំ២០១៨** ........ **២៦**
ក. ថវិការាជធានី ខេត្ត ........ ២៦
ខ. ថវិកាក្រុង ស្រុក ........ ២៦
គ. ថវិកាឃុំ សង្កាត់ ........ ២៦
IV. **ការគ្រប់គ្រង ផ.ស.ថ. ឆ្នាំ២០១៨** ........ **២៨**
ក. ការគ្រប់គ្រង និងការអនុវត្តសកម្មភាព ........ ២៨
ខ. ការគ្រប់គ្រង និងការអនុវត្តថវិកា ........ ២៨
គ. ការរៀបចំរបាយការណ៍ ........ ២៩
**ឧបសម្ព័ន្ធ**
**ឧបសម្ព័ន្ធទី១ ៖** សកម្មភាព និងថវិកានៃ ផ.ស.ថ. ឆ្នាំ២០១៨ ........ ៣០
**ឧបសម្ព័ន្ធទី២ ៖** ថវិកាគាំទ្រ ផ.ស.ថ. ឆ្នាំ២០១៨ តាមស្ថាប័នអនុវត្ត និងដៃគូ ........ ៦៦

# បញ្ជីតារាង


តារាងទី១ ៖ លទ្ធផលរំពឹងទុកជាអាទិភាពឆ្នាំ២០១៨ ........................................................ ២
តារាងទី២ ៖ ផែនការចំណាយសរុបសម្រាប់ឆ្នាំ២០១៨........................................................ ៨
តារាងទី៣ ៖ ផែនការចំណាយសរុបតាមប្រភេទមូលនិធិ ........................................................ ៩
តារាងទី៤ ៖ ថវិកាចំណាយសម្រាប់ការងារស្នូលនៃកំណែទម្រង់តាមប្រភេទស្ថាប័ន ............ ៩
តារាងទី៥ ៖ ថវិកាផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភពផ្ដល់មូលនិធិ .................. ១០
តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីមួយ........................................ ១៣
តារាងទី៧ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីមួយ..................................... ១៤
តារាងទី៨ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីពីរ ........................................... ១៦
តារាងទី៩ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីពីរ........................................ ១៧
តារាងទី១០ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីបី......................................... ១៩
តារាងទី១១ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបី ...................................... ១៩
តារាងទី១២ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីបួន....................................... ២១
តារាងទី១៣ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបួន .................................... ២២
តារាងទី១៤ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីប្រាំ ....................................... ២៥
តារាងទី១៥ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីប្រាំ.................................... ២៥
តារាងទី១៦ ៖ ការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ............................ ២៧
តារាងទី១៧ ៖ តារាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨...................................... ៣១
តារាងទី១៨ ៖ ថវិកាចំណាយសម្រាប់ការងារស្នូលនៃកំណែទម្រង់តាមស្ថាប័ន................. ៦៦
តារាងទី១៩ ៖ ថវិកាកម្ចីសម្រាប់ការងារកំណែទម្រង់ .................................................. ៦៧
តារាងទី២០ ៖ ថវិកាជំនួយឥតសំណងគាំទ្រដោយគម្រោងនានារបស់ដៃគូអភិវឌ្ឍ ........... ៦៨

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ទី១ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី១ (២០១១-២០១៤) នៃកម្មវិធីជាតិ |
| ផអ៣ទី២ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិ |
| ផអ៣ទី៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក. | គណកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| RGC | រាជរដ្ឋាភិបាល |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| CPs | រាជធានី ខេត្ត |
| DMKs | ក្រុង ស្រុក ខណ្ឌ |
| PDoWA | មន្ទីរកិច្ចការនារី |
| PDoP | មន្ទីរផែនការរាជធានី ខេត្ត |
| I4C | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ការអនុវត្តផែនការគណនេយ្យភាពសង្គម |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| GIZ/RED III | គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ដំណាក់កាលទី៣ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំកម្មវិធី |
| ADB/DPFSM | កម្មវិធីស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ |
| ADB/TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប |
| ADB/CDRR | គម្រោងគ្រប់គ្រងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន |
| ADB/SPCR | កម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ |
| ADB/NASLA | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| IFAD | មូលនិធិអន្តរជាតិសម្រាប់កិច្ចអភិវឌ្ឍកសិកម្ម |
| IFAD/ASPIRE | គម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ |
| SDC | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍របស់ប្រទេសស្វីស |
| UNCDF | មូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNCDF/LGCCII | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ |
| UNICEF/ Seth Koma | កម្មវិធីសិទ្ធិកុមារនៃមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |

| **អក្សរកាត់** | **ពាក្យពេញ** |
|---|---|
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |
| WB/LASED II | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហានទី២ |
| GiZ/DAR | កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ |
| USAID | ទីភ្នាក់ងារសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក |
| RACHA | អង្គការសម្ព័ន្ធភាពកុមារ និងសុខភាពបន្តពូជ |
| PACT | អង្គការ ផេក កម្ពុជា (អង្គការពង្រឹងសមត្ថភាពផ្នែកអភិបាលកិច្ច) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន |
| CSOs | អង្គការសង្គមស៊ីវិល |
| DFAT | នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី |
| OXFAM | អង្គការ OXFAM |
| NCDDS | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| PADD | អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| PMSD | អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| MEID | អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| AFD | អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| IAG | ក្រុមសវនកម្មផ្ទៃក្នុងនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| MOI | ក្រសួងមហាផ្ទៃ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MCS | ក្រសួងមុខងារសាធារណៈ |
| MOP | ក្រសួងផែនការ |
| MOWA | ក្រសួងកិច្ចនារី |
| ASAC | សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOE | ក្រសួងបរិស្ថាន |
| MOH | ក្រសួងសុខាភិបាល |
| MOT | ក្រសួងទេសចរណ៍ |
| MRD | ក្រសួងអភិវឌ្ឍជនបទ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MOC | ក្រសួងពាណិជ្ជកម្ម |

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| MoWRM | ក្រសួងធនធានទឹក និងឧតុនិយម |
| MLMUPC | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MPWT | ក្រសួងសាធារណៈការ និងដឹកជញ្ជូន |

# I. សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី៣ (ផអ៣ទី៣) ជាផែនការអនុវត្តដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១៩-២០២០) បរិយាយអំពីកិច្ចដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការរបស់រាជរដ្ឋាភិបាលពីឆ្នាំ២០១៨-២០២០។ ផអ៣ទី៣ នឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នចំនួន២១ រាជធានី ខេត្តចំនួន២៥ និងក្រុង ស្រុក ខណ្ឌចំនួន ១៩៧។ ផអ៣ទី៣ ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ក្រុង ស្រុក ទោះបីជាផែនការនេះនឹងអនុវត្តនៅគ្រប់ថ្នាក់រដ្ឋបាលទាំងអស់ក៏ដោយ។ ទិដ្ឋភាពទូទៅអំពីចក្ខុវិស័យ គោលបំណង គោលដៅ សមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុកនៃផអ៣ទី៣ មានបង្ហាញដោយសង្ខេបក្នុងរូបភាពដូចខាងក្រោម។

**ខ្សែចង្វាក់លទ្ធផលនៃ ផអ៣ទី៣**




ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨របស់ គ.ជ.អ.ប. (ផ.ស.ថ.) រៀបរាប់អំពីផទ្ធផលរំពឹងទុកជាអាទិភាពដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨ ព្រមទាំងលទ្ធផលរំពឹងសំខាន់ៗផ្សេងទៀត សកម្មភាពនានា ពេលវេលាអនុវត្ត និងថវិកាដែលត្រូវការសម្រាប់ការអនុវត្តលទ្ធផលរំពឹងទុក និងសកម្មភាពទាំងនោះ។

ផ.ស.ថ. ឆ្នាំ២០១៨ ត្រូវបានរៀបចំឡើង តាមរយៈកិច្ចដំណើរការដែលមានការចូលរួម និងការការប្រឹក្សាយោបល់ជាមួយស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា ដែលបានរៀបចំឡើងក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០១៧ដល់មករា ឆ្នាំ២០១៨។ បន្ទាប់មក សេចក្តីព្រាងចុងក្រោយនៃ ផ.ស.ថ. ត្រូវបានបង្ហាញក្នុងសន្និសីទជាតិស្តីពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ “ *មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងទិសដៅទៅអនាគតនៃ* ” ដែលបានរៀបចំឡើងកាលពីថ្ងៃ០៧-០៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១-

២២ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានសិក្ខាកាមចូលរួមសរុបប្រមាណ២.៧០០នាក់ រួមមានតំណាងមកពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ផ្អែកលើមតិយោបល់របស់សន្និសីទជាតិ ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប. បានពិនិត្យកែសម្រួល និងរៀបចំជាសេចក្តីព្រាងឯកសារចុងក្រោយនៃ ផ.ស.ថ. ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត។

ឯកសារ ផ.ស.ថ. ឆ្នាំ២០១៨ បែងចែកជា៤ផ្នែក។ ផ្នែកទី១ជាសេចក្តីផ្តើមដែលបរិយាយអំពីលទ្ធផលរំពឹងទុកជាអាទិភាពដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨ ផែនការចំណាយ និងប្រភពផ្តល់មូលនិធិឆ្នាំ២០១៨។ ផ្នែកទី២ជាផ្នែកមួយដ៏មានសារៈសំខាន់ រៀបរាប់អំពីលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពតាមសមាសភាគទាំង៥នៃផអ៣ទី៣ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៨។ ផ្នែកទី៣បរិយាយអំពីធនធានហិរញ្ញវត្ថុ ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលទាំងមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្នែកទី៤រៀបរាប់អំពីបែបផែនការនៃការគ្រប់គ្រង និងការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប.។ ព័ត៌មានលម្អិតអំពីសកម្មភាពនៃ ផ.ស.ថ. ឆ្នាំ២០១៨ រួមបញ្ចូលទាំងថវិកា ស្ថាប័នអនុវត្ត និងពេលវេលាអនុវត្ត និងព័ត៌មានអំពីថវិកានៃ ផ.ស.ថ. តាមស្ថាប័នអនុវត្ត និងតាមដៃគូអភិវឌ្ឍមានរៀបរាប់ក្នុងឧបសម្ព័ន្ធ។

## ក. លទ្ធផលរំពឹងទុកជាអាទិភាពឆ្នាំ២០១៨

ផ.ស.ថ. ឆ្នាំ២០១៨ មានលទ្ធផលរំពឹងទុកសរុបចំនួន**៦៧**។ ផ្អែកលើលទ្ធផលរំពឹងទុកទាំងនេះ គ.ជ.អ.ប. បានកំណត់លទ្ធផលរំពឹងទុកជាអាទិភាពចំនួន**៣៣**ដែលត្រូវសម្រេចឱ្យបាន។ តារាងខាងក្រោមបរិយាយអំពីលទ្ធផលរំពឹងទុកជាអាទិភាពទាំង៣៣ រួមបញ្ចូលទាំងសកម្មភាព/ចំណុចដៅដែលត្រូវសម្រេចតាមត្រីមាសនីមួយៗ។

**តារាងទី១ ៖ លទ្ធផលរំពឹងទុកជាអាទិភាពក្នុងឆ្នាំ២០១៨**

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| ១. ការពិនិត្យមើលឡើងវិញផ្នែកស្ថាប័នរបស់រាជធានី ខេត្ត និងក្រុង ស្រុក ត្រូវបានអនុវត្ត (១.១.១.១) | • ការពិនិត្យមើលឡើងវិញផ្នែកស្ថាប័នរបស់ក្រុង ស្រុក រួមបញ្ចូលទាំងមុខងារក្នុងការគាំទ្រ និងផ្តល់សេវារដ្ឋបាលដល់ឃុំ សង្កាត់ | ទី២ |
| ២. លេខាធិការដ្ឋាន គ.ជ.អ.ប. ក្លាយជាអង្គភាពថវិកាក្នុងឆ្នាំ២០១៩ (១.១.១.២) | • លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនានាសម្រាប់ការបង្កើតលេខាធិការដ្ឋាន គ.ជ.អ.ប. ជាអង្គភាពថវិកា | ទី៣ |
| ៣. សកម្មភាពនានារបស់ផអ៣ទី៣ត្រូវបានបញ្ចូលក្នុងផែនការសកម្មភាព និងថវិការបស់រាជរដ្ឋាភិបាល | • ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ របស់ក្រសួង ស្ថាប័នចំនួន២១ រាជធានី ខេត្តចំនួន២៥ និងក្រុង ស្រុក ខណ្ឌចំនួន១៩៧ ដែលមានបញ្ចូលសកម្មភាពនានារបស់ | ទី២ |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| (១.១.៣.១) | ផអ៣ទី៣ ត្រូវបានរៀបចំ | |
| ៤. កិច្ចប្រជុំ គ.ជ.អ.ប. ត្រូវបានរៀបចំបានទៀងទាត់ចំនួន៣ ដើម្បីពិនិត្យមើលពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ព្រមទាំងពិភាក្សា និងអនុម័តអំពីគោលនយោបាយនានា (១.២.១.១) | • កិច្ចប្រជុំ គ.ជ.អ.ប. ត្រូវបានរៀបចំ៖<br>✓ យ៉ាងតិច កិច្ចប្រជុំចំនួន១<br>✓ យ៉ាងតិច កិច្ចប្រជុំសរុបចំនួន២<br>✓ យ៉ាងតិច កិច្ចប្រជុំសរុបចំនួន៣ | <br>ទី១<br>ទី៣<br>ទី៤ |
| ៥. សកម្មភាពនៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានដើម្បីលើកកម្ពស់វិមជ្ឈការ និងវិសហមជ្ឈការយ៉ាងតិចចំនួន២០លើក ត្រូវបានអនុវត្ត (១.២.២.១) | • យុទ្ធនាការផ្សព្វផ្សាយព័ត៌មានចំនួន១លើកស្តីពីការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋ ត្រូវបានអនុវត្ត<br>• ផែនការ និងសកម្មភាពប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានចំនួន៥ ដើម្បីគាំទ្រលទ្ធផលរំពឹងទុកផ្សេងទៀត ត្រូវបានរៀបចំ និងអនុវត្ត<br>• សេចក្តីប្រកាសព័ត៌មាន ឬការផ្សាយព័ត៌មាន តាមរយៈទស្សនាវដ្តី ដើម្បីលើកកម្ពស់វិមជ្ឈការ និងវិសហមជ្ឈការចំនួន៣លើកត្រូវបានរៀបចំ និងអនុវត្ត ៖<br>✓ ចំនួន១លើក<br>✓ សរុបចំនួន២លើក<br>✓ សរុបចំនួន៣លើក | ទី២<br><br>ទី៣<br><br><br><br><br><br>ទី២<br>ទី៣<br>ទី៤ |
| ៦. បែបផែននានានៃភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ត្រូវបានកំណត់ និងស្វែងរកមូលនិធិគាំទ្រ (១.៣.១.១) | • យុទ្ធសាស្ត្រនៃភាពជាដៃគូជាមួយសង្គមស៊ីវិលត្រូវបានរៀបចំ<br>• សកម្មភាពនៃភាពជាដៃគូជាមួយសង្គមស៊ីវិល ត្រូវបានបញ្ជ្រាបក្នុងលទ្ធផលរំពឹងទុកយ៉ាងតិចចំនួន៥ | ទី២<br><br>ទី៣ |
| ៧. ការងារគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីកការអនុវត្តក្នុងស្រុកគោលដៅចំនួន៩៨ (២.២.១.១) | • ពិនិត្យមើលឡើងវិញអំពីទិន្នន័យលទ្ធផលការងារដែលបានអនុវត្តក្នុងវិស័យទាំងបី<br>• ប្រមូល និងផលិតផ្ទាំងព័ត៌មានសម្រាប់បិតផ្សាយ<br>• រៀបចំផែនការអនុវត្តរយៈពេលប្រាំឆ្នាំស្តីពីការងារគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់ | ទី១<br><br>ទី៣<br>ទី៤ |
| ៨. យន្តការដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត និងដំណើរការ (២.១.២.១) | • ការិយាល័យប្រជាពលរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវបានបង្កើតទូទាំងប្រទេស<br>• ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកចំនួន៣០ត្រូវបានបង្កើត<br>• សេចក្តីណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានអនុម័ត | ទី៣<br><br>ទី៤<br><br>ទី៤ |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| ៩. កម្មវិធីដើម្បីបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងបច្ចេកទេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រីក និងអនុវត្ត (២.៥.១.១) | • តម្រូវការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីក្នុងមុខតំណែងដឹកនាំយ៉ាងតិចចំនួន៥០នាក់ត្រូវបានកំណត់<br>• អភិវឌ្ឍសមត្ថភាពរបស់ស្ត្រីក្នុងមុខតំណែងដឹកនាំដែលបានកំណត់<br>• យុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរួមបញ្ចូលទាំងស្ត្រីជា ជនពិការ និងជនជាតិដើមភាគតិចត្រូវបានពិនិត្យ និងកែសម្រួល | ទី២<br>ទី៣<br>ទី៤ |
| ១០. កម្មវិធីអភិវឌ្ឍសមត្ថភាព និងការបង្កើនចំណេះដឹងរបស់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានអនុវត្ត (២.៥.១.២) | • វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់រាជធានី ខេត្ត (១០រាជធានី ខេត្ត) ត្រូវបានរៀបចំ<br>• វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្ត | ទី២<br>ទី៤ |
| ១១. កិច្ចដំណើរការគ្រប់គ្រងធនធានតាមបែបវិមជ្ឈការត្រូវបានអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៣.១.១.១) | • វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសស្តីពីការគ្រប់គ្រងបុគ្គលិកតាមបែបវិមជ្ឈការត្រូវបានអនុវត្ត<br>• វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបុគ្គលិកតាមបែបវិមជ្ឈការត្រូវបានរៀបចំ | ទី១<br>ទី២ |
| ១២. កិច្ចដំណើរការនៃការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការត្រូវបានពិនិត្យ និងកែលម្អ (៣.២.១.១) | • ស្តង់ដាសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ<br>• សេចក្តីណែនាំស្តីពីការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំ | ទី២<br>ទី២ |
| ១៣. កម្មវិធីអភិវឌ្ឍសមត្ថភាពរបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្ត ផ្អែកតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពរបស់ផអ៣ទី៣ និងផែនការប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ(៣.២.២.១) | • សកម្មភាពអភិវឌ្ឍសមត្ថភាពនៃផែនការអន្តរាគមន៍អភិវឌ្ឍសមត្ថភាពរបស់រាជធានី ខេត្តត្រូវបានអនុវត្ត ៖<br>✓ យ៉ាងតិច៣០%នៃផែនការ<br>✓ យ៉ាងតិចចំនួនសរុប៦០%នៃផែនការ<br>✓ យ៉ាងតិចចំនួនសរុប៨០%នៃផែនការ | <br><br>ទី២<br>ទី៣<br>ទី៤ |
| ១៤. លិខិតបទដ្ឋានសម្រាប់ការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានកែលម្អ និងភាពជាដៃគូក្នុងការផ្តល់សេវា ត្រូវបានលើកកម្ពស់ (៤.១.១.១) | • លិខិតបទដ្ឋាន សេចក្តីណែនាំ និងនីតិវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ភាពជាដៃគូ និងបញ្ហានានាដែលពាក់ព័ន្ធការកំណត់ និងការអនុវត្តមុខងារជាអាណត្តិទូទៅ ត្រូវបានពិនិត្យមើលឡើងវិញ<br>• នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុនានាពាក់ព័ន្ធនឹងមុខងារជាអាណត្តិទូទៅ ត្រូវបានពិនិត្យ និងកែសម្រួល | ទី២<br>ទី៤ |
| ១៥. សេចក្តីណែនាំ និងនីតិវិធីស្តីពីការគ្រប់គ្រង និងការអនុវត្តកញ្ចប់ថវិកា | • សេចក្តីណែនាំ និងនីតិវិធីសម្រាប់ការសាកល្បងនូវកញ្ចប់ថវិកាទាំង៣ប្រភេទ ត្រូវបានអនុម័ត | ទី៣ |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| សម្រាប់ការផ្តល់សេវាក្នុងភាពជាដៃគូជាមួយសហគមន៍ជាមួយសង្គមស៊ីវិល និងជាមួយផ្នែកឯកជនត្រូវបានរៀបចំ (៤.១.៣.១) | • ឯកសារ និងសម្ភារៈសម្រាប់ការបណ្តុះបណ្តាលក្នុងឆ្នាំ ២០១៩ ត្រូវបានរៀបចំ | ទី៤ |
| ១៦. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានរៀបចំ (៤.២.១.២) | • បញ្ចប់ការសិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី២<br>ទី៤<br>ទី៤ |
| ១៧. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានរៀបចំ (៤.២.១.៣) | • ការសិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី២<br>ទី៤ |
| ១៨. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងបរិស្ថាន ត្រូវបានរៀបចំ (៤.២.១.៤) | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ<br>• អនុវត្តការវាយតម្លៃអំពីការអនុវត្តមុខងារដែលបានផ្ទេរ | ទី១<br>ទី២<br>ទី២<br>ទី៤ |
| ១៩. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងសុខាភិបាល ត្រូវបានរៀបចំ (៤.២.១.៥) | • សិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី២<br>ទី៤<br>ទី៤ |
| ២០. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុ | • សិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការ | |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| វត្តការផ្ទេរមុខងាររបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូនត្រូវបានរៀបចំ (៤.២.១.៦) | ផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី២<br>ទី៤<br>ទី៤ |
| ២១. លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងទេសចរណ៍ ត្រូវបានរៀបចំ (៤.២.១.៧) | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី៣<br>ទី៤ |
| ២២. លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរៀបចំ (៤.២.១.៨) | • សិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី២<br>ទី៣<br>ទី៤ |
| ២៣. លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានរៀបចំ (៤.២.១.៩) | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី១<br>ទី២ |
| ២៤. លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងរ៉ែ និងថាមពល ត្រូវបានរៀបចំ (៤.២.១.១០) | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ | ទី២ |
| ២៥. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំ (៤.២.១.១១) | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការផ្ទេរមុខងារ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលសមត្ថភាពស្តីពីមុខងារដែលបានផ្ទេរ | ទី១<br>ទី២ |
| ២៦. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួងធនធានទឹក និងឧតុនិយម ត្រូវបាន | • ពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារ<br>• ពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ | ទី១<br>ទី២ |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| រៀបចំ (៤.២.១.១២) | • សិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសសម្រាប់ផ្ទេរ និងអនុវត្តមុខងារ<br>• រៀបចំផ្សព្វផ្សាយ និងវគ្គអភិវឌ្ឍសមត្ថភាពស្តីពីលិខិតបទដ្ឋានដែលបានអនុម័ត | ទី២<br>ទី៤<br>ទី៤ |
| ២៧. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានរៀបចំ (៤.២.១.១៣) | • ពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារ<br>• ពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ | ទី២<br>ទី៣ |
| ២៨. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួង គ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានរៀបចំ (៤.២.១.១៤) | • ពិនិត្យ និងរៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ<br>• រៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសសម្រាប់ផ្ទេរ និងអនុវត្តមុខងារ | ទី២<br>ទី៣ |
| ២៩. លិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តការផ្ទេរមុខងាររបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំ (៤.២.១.១៥) | • សិក្សា និងវិភាគអំពីធនធាន និងតម្រូវការនានាក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសសម្រាប់ផ្ទេរ និងអនុវត្តមុខងារ | ទី៣<br>ទី៤ |
| ៣០. ការបង្កើត និងកិច្ចដំណើរការនៃអង្គភាពច្រកចេញចូលតែមួយនៅថ្នាក់រាជធានី ខេត្តចំនួន២៥ (៤.២.៤.១) | • សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>• វគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ច និងការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ត្រូវបានអនុវត្ត<br>• អង្គភាពសេវាច្រកចេញចូលតែមួយថ្មីចំនួន២៥ ត្រូវបានបង្កើត | ទី១<br>ទី១<br>ទី៤ |
| ៣១. ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន៨២ (៤.២.៤.២) | • ផ្សព្វផ្សាយអំពីនីតិវិធីនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការជ្រើសរើសបុគ្គលិកនៅស្រុកគោលដៅថ្មីចំនួន៣០<br>• វគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ច និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់ការិយាល័យច្រកចេញចូលតែមួយស្រុកគោលដៅថ្មីចំនួន៣០<br>• ការិយាល័យសេវាច្រកចេញចូលតែមួយថ្មីចំនួន៣០ ត្រូវបានបង្កើត | ទី២<br>ទី៣<br>ទី៤ |

| លទ្ធផលរំពឹងទុកជាអាទិភាព | សកម្មភាព/ ចំណុចដៅដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| ៣២. មូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានពិនិត្យ និងកែសម្រួលផ្តោតលើចំណាយផ្នែកអភិវឌ្ឍ និងសាកល្បងកញ្ចប់ថវិកាសម្រាប់ការបំពេញមុខងារ (៥.១.១.១) | • លិខិតបទដ្ឋានគតិយុត្តនានាស្តីពីមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ក្នុងការកំណត់ចំណាយផ្នែករដ្ឋបាល និងចំណាយផ្នែកអភិវឌ្ឍ ត្រូវបានពិនិត្យ និងកែសម្រួល<br>• រូបមន្តនៃការបែងចែកមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ រួមបញ្ចូលទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធត្រូវបានពិនិត្យ និងកែសម្រួល<br>• សេចក្តីណែនាំស្តីពីការសាកល្បងកញ្ចប់ថវិកាសម្រាប់ការបំពេញការងារនៃពាក់ព័ន្ធនឹងមូលនិធិក្រុង ស្រុក សម្រាប់អនុវត្តក្នុងឆ្នាំ២០១៩ ត្រូវបានរៀបចំ | ទី១<br>ទី២<br>ទី៣ |
| ៣៣. ការពិនិត្យ និងការកែសម្រួលបែបផែននៃការបែងចែកចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីបង្កើនការផ្តល់ធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ(៥.១.២.១) | • ការពិនិត្យមើលឡើងវិញអំពីចំណូលមិនមែនសារពើពន្ធថ្នាក់ខេត្ត ដើម្បីផ្ទេរទៅឱ្យក្រុង ស្រុកត្រូវបានអនុវត្ត<br>• លិខិតបទដ្ឋាននានាស្តីពីចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធត្រូវបានពិនិត្យ និងកែសម្រួល | ទី២<br>ទី៤ |

## ២. ផែនការចំណាយ និងប្រភពមូលនិធិឆ្នាំ២០១៨

### ២.១. ផែនការចំណាយ

តារាងទី១ខាងក្រោមសង្ខេបពីផែនការនៃថវិកាចំណាយសរុបរបស់ ផ.ស.ថ. ឆ្នាំ២០១៨របស់ គ.ជ.អ.ប.។ ក្នុងឆ្នាំ២០១៨ ថវិកាប៉ាន់ស្មានសរុបនៃ ផ.ស.ថ. មានចំនួន១,៩ទ្រីលានរៀលក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន១,៧ទ្រីលានរៀល ថវិកាកម្ចីមានចំនួន១០៧ប៊ីលាន និងថវិកាជំនួយឥតសំណងរបស់ដៃគូអភិវឌ្ឍនានាមានចំនួន៩២ប៊ីលានរៀល។

**តារាងទី២ ៖ ផែនការចំណាយសរុបសម្រាប់ឆ្នាំ២០១៨**

| ប្រភេទថវិកាចំណាយ | ថវិការាជរដ្ឋាភិបាល | ថវិកាកម្ចី | ថវិកាជំនួយឥតសំណង | សរុប | % |
|---|---|---|---|---|---|
| **១. ការងារកំណែទម្រង់** | **67,798,003,730** | **107,542,877,850** | **76,290,476,697** | **251,631,358,277** | 13.02% |
| សមាសភាគទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់ | 8,589,190,750 | 0 | 13,838,202,000 | **22,427,392,750** | 1.16% |
| សមាសភាគទី២ ៖ អភិបាលកិច្ចល្អ | 9,458,330,615 | 0 | 24,025,377,600 | **33,483,708,215** | 1.73% |
| សមាសភាគទី៣ ៖ ការគ្រប់គ្រងធនធានមនុស្ស | 9,056,288,215 | 0 | 12,418,871,400 | **21,475,159,615** | 1.11% |
| សមាសភាគទី៤ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន | 38,451,907,600 | 91,342,877,850 | 23,453,690,697 | **153,248,476,147** | 7.93% |
| សមាសភាគទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ | 2,242,286,550 | 16,200,000,000 | 2,554,335,000 | **20,996,621,550** | 1.09% |
| **២. ធនធានហិរញ្ញវត្ថុផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | **1,665,157,426,370** | **0** | **16,200,000,000** | **1,681,357,426,370** | 86.98% |
| **សរុបរួម** | **1,732,955,430,100** | **107,542,877,850** | **92,490,476,697** | **1,932,988,784,647** | **100%** |

### ២.២. ប្រភពមូលនិធិ

ជារៀងរាល់ឆ្នាំ មួយភាគធំនៃថវិកាចំណាយរបស់ ផ.ស.ថ. ជាថវិកាគាំទ្រដោយរាជរដ្ឋាភិបាល។ ក្នុងឆ្នាំ២០១៨ ថវិកាចំណាយរបស់ ផ.ស.ថ. គាំទ្រដោយរាជរដ្ឋាភិបាលមានចំនួនសរុបប្រមាណ១,៧ ទ្រីលានរៀល ស្មើនឹង៩០% និងថវិកាគាំទ្រដោយដៃគូអភិវឌ្ឍមានចំនួនសរុបប្រមាណ១៩៩ប៊ីលានរៀល ស្មើនឹង១០%។

**តារាងទី៣ ៖ ផែនការថវិកាចំណាយសរុបតាមប្រភេទមូលនិធិ**

| ល.រ. | ប្រភេទថវិកា | រាជរដ្ឋាភិបាល | ដៃគូអភិវឌ្ឍ | សរុប |
|---|---|---|---|---|
| ១. | ធនធានហិរញ្ញវត្ថុផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | 1,665,157,426,370 | 49,446,255,600 | **1,714,603,681,970** |
| ២. | សកម្មភាពស្នូលនៃកំណែទម្រង់ | 54,303,197,180 | 29,020,356,000 | **83,323,553,180** |
| ៣. | គម្រោង កម្មវិធីដាច់ដោយឡែកនានា | 13,867,001,550 | 121,194,547,947 | **135,061,549,497** |
| | **សរុបរួម** | **1,733,327,625,100** | **199,661,159,547** | **1,932,988,784,647** |

ក្នុងឆ្នាំ២០១៨ ថវិកាចំណាយសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ ដែលគាំទ្រដោយដោយរាជរដ្ឋបាលភិបាលមានកើនឡើងយ៉ាងច្រើនមានចំនួនសរុបប្រមាណ៥៤ប៊ីលានរៀល ស្មើនឹង៦៥% ក្នុងនោះថវិកាក្រសួង ស្ថាប័ន មានចំនួន២២% ថវិការបស់រាជធានី ខេត្តមានចំនួន៣២% ថវិការបស់ក្រុង ស្រុក ខណ្ឌមានចំនួន១០% និងថវិកាបដិភាគរបស់ដៃគូអភិវឌ្ឍមានចំនួនប្រមាណ២៩ប៊ីលានរៀល ស្មើនឹង៣៥%។

**តារាងទី៤ ៖ ថវិកាចំណាយសម្រាប់គាំទ្រការងារស្នូលនៃកំណែទម្រង់តាមប្រភេទស្ថាប័ន**

| ស្ថាប័នអនុវត្ត | ថវិកា | ភាគរយ |
|---|---|---|
| ក្រសួង ស្ថាប័ន | 18,205,730,700 | 21.85% |
| រាជធានី ខេត្ត | 27,027,811,735 | 32.44% |
| ក្រុង ស្រុក ខណ្ឌ | 9,069,654,745 | 10.88% |
| **សរុបរង** | **54,303,197,180** | **65.17%** |
| ដៃគូអភិវឌ្ឍ (EU និង SDC) | 29,020,356,000 | 34.83% |
| **សរុបរង** | **29,020,356,000** | **34.83%** |
| **សរុបរួម** | **83,323,553,180** | **100%** |

ក្នុងឆ្នាំ២០១៨ ថវិកាផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសរុបមានចំនួន១,៧ទ្រីលានរៀល ក្នុងនោះ ថវិកាគាំទ្រដោយរាជរដ្ឋភិបាលមានចំនួនប្រមាណ១,៦ទ្រីលានរៀល ស្មើនឹង៩៧% និងថវិកាបដិភាគរបស់ដៃគូអភិវឌ្ឍមានចំនួន៤៩ប៊ីលានរៀល ស្មើនឹង៣%។

## តារាងទី៥ ៖ ថវិកាផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភពផ្តល់មូលនិធិ

| រដ្ឋបាលថ្នាក់ក្រោមជាតិ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | សរុប |
|---|---|---|---|
| រាជធានី ខេត្ត | 1,064,215,757,115 | 0 | **1,064,215,757,115** |
| ក្រុង ស្រុក ខណ្ឌ | 166,900,536,755 | 33,412,500,000 | **200,313,036,755** |
| ឃុំ សង្កាត់ | 434,041,132,500 | 16,033,755,600 | **450,074,888,100** |
| **សរុបរួម** | **1,665,157,426,370** | **49,446,255,600** | **1,714,603,681,970** |

## II. សមាសភាគនានានៃ ផ.ស.ថ. ២០១៧

ផ្នែកទី២នេះ គឺជាផ្នែកមួយដ៏សំខាន់នៃឯកសារ ផ.ស.ថ. ឆ្នាំ២០១៨ និងបែងចែកជា៥សមាសភាគ ស្របតាមផអ៣ទី៣ រួមមានដូចខាងក្រោម ៖

១. ការគ្រប់គ្រងការងារកំណែទម្រង់

២. អភិបាលកិច្ចល្អ

៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

៤. ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន

៥. វិមជ្ឈការហិរញ្ញវត្ថុ

ជារួម ក្នុងសមាសភាគនីមួយៗមានបរិយាយអំពីសេចក្តីផ្តើម គោលដៅនិងសមិទ្ធផលរំពឹងទុក សូចនាករនិងចំណុចដៅ និងលទ្ធផលរំពឹងទុកដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨។

សកម្មភាពលម្អិតរួមបញ្ចូលទាំងស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត ថវិកា ប្រភពមូលនិធិ និង ពេលវេលាអនុវត្តមានរៀបរាប់នៅក្នុងផ្នែកទី៤។

# សមាសភាគទីមួយ ៖ ការគ្រប់គ្រងការងារកំណែទម្រង់

## ក. សេចក្តីផ្តើម

ភាពជោគជ័យនៃផអ៣ដំណាក់កាលទី៣ អាស្រ័យលើប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចដំណើរការនានានៃកំណែទម្រង់។ សមាសភាគទី១នេះផ្តោតលើការពង្រឹងភាពជាម្ចាស់ និងនិរន្តរភាពផ្នែកស្ថាប័ន និងផ្នែកហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការលើកកម្ពស់វប្បធម៌នៃការសិក្សារៀនសូត្រ និងភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការងារកំណែទម្រង់។ កិច្ចការទាំងនេះនឹងត្រូវធ្វើឡើងតាមរយៈការពង្រឹងកិច្ចពិភាក្សាកម្រិតនយោបាយរវាង គ.ជ.អ.ប. ជាមួយថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការងារកំណែទម្រង់ឱ្យបានទៀងទាត់ ដើម្បីលើកកម្ពស់ការសម្របសម្រួល និងសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល និងគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍ។ ជាមួយគ្នានេះដែរ សមាសភាគទីមួយក៏ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងនូវការអនុវត្តយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន និងកិច្ចដំណើរការនៃការរៀបចំគោលនយោបាយនិងលិខិតបទដ្ឋាននានាតាមរយៈការសាកល្បង ការសិក្សារៀនសូត្រ និងការត្រួតពិនិត្យ និងការវាយតម្លៃ។

## ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក

សមាសភាគទីមួយមានគោលដៅ **លើកកម្ពស់ការគ្រប់គ្រងការងារកំណែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**។ សមិទ្ធផលសំខាន់ៗដែលត្រូវសម្រេចបានរួមមាន ៖

- និរន្តរភាព និងស្ថាប័នភាវូបនីយកម្មនៃការងារកំណែទម្រង់នានាត្រូវបានលើកកម្ពស់
- ភាពជាម្ចាស់ និងការគាំទ្រដល់កំណែទម្រង់ត្រូវបានពង្រឹងយ៉ាងទូលំទូលាយ
- សង្គមស៊ីវិល និងផ្នែកឯកជនក្លាយជាដៃគូជាមួយរដ្ឋាភិបាលក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ផអ៣ទី៣ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

## គ. សូចនាករ និងចំណុចដៅ

សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨មានចំនួន ១៨ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម។

## តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីមួយ

| ល.រ. | សូចនាករ | ចំណុចដៅ | |
|---|---|---|---|
| | | ដើមគ្រា | ២០១៨ |
| ១. | ចំនួនការពិនិត្យមើលឡើងវិញផ្នែកស្ថាប័នរបស់រាជធានី ខេត្ត និងក្រុង ស្រុក | ០ | ១ |
| ២. | លេខាធិការដ្ឋាន គ.ជ.អ.ប. ក្លាយជាអង្គភាពថវិកា | | បានរៀបចំ |
| ៣. | ថវិកាសម្រាប់កំណែទម្រង់ស្នូលគាំទ្រដោយរាជរដ្ឋាភិបាល (គិតជាលានដុល្លារ) | ២,៨ | ១,០ |
| ៤. | ថវិកាដៃគូគាំទ្រជំនួយបច្ចេកទេសរយៈពេលវែង (គិតជាលានដុល្លារ) | | ៤ |
| ៥. | ថវិកាដៃគូគាំទ្រប្រតិបត្តិការនៃផអ៣ទី៣ (គិតជាលានដុល្លារ) | ០ | ២ |
| ៦. | ភាគរយចំណាយសមាគមក្រុមប្រឹក្សាទទួលបានពីប្រាក់សមាជិកភាព | ២ | ១០ |
| ៧. | ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | ៣ | ៣ |
| ៨. | សកម្មភាពផ្សព្វផ្សាយការផ្លាស់ប្តូរឥរិយាបថចំនួន១ កម្មវិធីទូរទស្សន៍ចំនួន១... | ០ | អនុវត្ត |
| ៩. | ចំនួនលទ្ធផលរំពឹងទុករបស់ ផ.ស.ថ. អនុវត្តការប្រាស្រ័យទាក់ទង | ០ | ៥ |
| ១០ | មេរៀនបទពិសោធន៍ល្អៗរបស់ SNAs ត្រូវបានចងក្រង និងផ្សព្វផ្សាយ | ០ | អនុវត្ត |
| ១១. | កម្មវិធីនៃភាពជាដៃគូបានកំណត់ និងផ្តល់ហិរញ្ញប្បទាន | | រៀបចំ |
| ១២. | ចំនួនលទ្ធផលរំពឹងទុកនៃ ផ.ស.ថ. សហការជាមួយសង្គមស៊ីវិលឯកជន | ៧៩ | ៥ |
| ១៣. | ភាគរយនៃលទ្ធផលរំពឹងទុកបានរៀបចំជាគម្រោងបានអនុម័ត | ២៥ | ៦០ |
| ១៤. | ភាគរយនៃទិន្នន័យសូចនាករ ផអ៣ទី៣ បានប្រមូល និងចងក្រង | | ៩០ |
| ១៥. | ភាគរយនៃចំណុចដៅ ផអ៣ទី៣ ដែលបានសម្រេច | | ៥០ |
| ១៦. | ភាគរយនៃចំណុចដៅនៃ ផ.ស.ថ. ដែលបានសម្រេច | | ៨០ |
| ១៧. | ការសិក្សាឯករាជ្យបានអនុម័តដោយ TWG-SNDD | | អនុម័ត |
| ១៨. | ចំនួនហានិភ័យកម្រិតខ្ពស់ និងមធ្យមកំណត់ក្នុងរបាយការណ៍សវនកម្ម | | ១១ |

### ឃ. លទ្ធផលរំពឹងទុក និងថវិកា

សមាសភាគទីមួយមានលទ្ធផលរំពឹងទុកចំនួន១៦ ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨ដូចមានរៀបរាប់ក្នុងតារាងទី៧ខាងក្រោម។

ផែនការចំណាយថវិកាសរុបរបស់សមាសភាគនេះមានចំនួនសរុប២២ពាន់លានរៀល ដែលក្នុងនោះរួមមានថវិកាគាំទ្ររបស់រាជរដ្ឋាភិបាលចំនួន៨ពាន់លានរៀល និងថវិកាគាំទ្ររបស់ដៃគូអភិវឌ្ឍនានាមានចំនួន១៤ពាន់លានរៀល។

តារាងសមាសភាគ សមិទ្ធផល លទ្ធផលរំពឹងទុក សកម្មភាព និងថវិកាលម្អិតនៃ ផ.ស.ថ. ឆ្នាំ ២០១៨ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី១។

## តារាងទី៧ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីមួយ

| លេខកូដ | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 1.1.1.1 | ការពិនិត្យមើលឡើងវិញផ្នែកស្ថាប័នរបស់រាជធានី ខេត្ត និងក្រុង ស្រុក | 101,250,000 |
| 1.1.1.2 | ការរៀបចំលេខាធិការដ្ឋាន គ .ប.អ.ជ.ឱ្យក្លាយជាអង្គភាពថវិកាក្នុងឆ្នាំ ២០១៩ ត្រូវបានអនុវត្ត | 4,050,000 |
| 1.1.3.1 | សកម្មភាពនានារបស់ផអ៣ទី៣ ត្រូវបានបញ្ចូលក្នុងផែនការសកម្មភាព និងថវិការបស់រាជរដ្ឋាភិបាល | 4,050,000 |
| 1.2.1.1 | កិច្ចប្រជុំ គ.ជ.អ.ប. ត្រូវបានរៀបចំបានទៀងទាត់ចំនួន៣ ដើម្បីពិនិត្យមើលពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ព្រមទាំងពិភាក្សា និងអនុម័តអំពីគោលនយោបាយនានា | 1,356,631,800 |
| 1.2.2.1 | សកម្មភាពនៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានដើម្បីលើកកម្ពស់វិមជ្ឈការ និងវិសហមជ្ឈការយ៉ាងតិចចំនួន២០លើក ត្រូវបានអនុវត្ត | 1,166,956,000 |
| 1.2.3.1 | ការសាកល្បង និងគោលនយោបាយនិងលិខិតបទដ្ឋាននានា ត្រូវបានអនុវត្ត និងរៀបចំ | 11,743,704,000 |
| 1.2.3.2 | កម្មវិធីសិក្សារៀនសូត្រដើម្បីផ្សព្វផ្សាយបទពិសោធន៍ៗយ៉ាងតិចចំនួន១០ ត្រូវបានរៀបចំ និងអនុវត្ត | 202,500,000 |
| 1.2.4.1 | តួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការស្វែងរកការគាំទ្រមតិ ត្រូវបានពង្រឹង | 2,358,880,950 |
| 1.3.1.1 | បែបផែននានានៃភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ត្រូវបានកំណត់ និងស្វែងរកមូលនិធិគាំទ្រ | 81,000,000 |
| 1.4.1.1 | ឯកសារគម្រោងនានានៃលទ្ធផលរំពឹងទុក និងបុគ្គលិកទទួលខុសត្រូវអនុវត្ត និងគ្រប់គ្រងគម្រោង ត្រូវបានរៀបចំ និងកំណត់ច្បាស់លាស់ | 0 |
| 1.4.1.2 | យុទ្ធសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃ និងក្របខ័ណ្ឌលទ្ធផលត្រូវបានអនុវត្ត | 281,151,000 |
| 1.4.1.3 | ផ.ថ.ស. ត្រូវបានរៀបចំ និងអនុវត្ត | 1,616,274,000 |
| 1.4.2.1 | អនុសាសន៍នានាស្តីពីការធ្វើសុខដុនីយកម្មនូវគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ត្រូវបានឯកភាព ដោយក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | 20,250,000 |
| 1.4.2.2 | សកម្មភាពដើម្បីលើកកម្ពស់កិច្ចសហការរវាងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាល សាធារណៈអំពីវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់ | 8,100,000 |
| 1.4.3.1 | សេវាគាំទ្រផ្នែករដ្ឋបាល និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូនស្ថាប័នអនុវត្តទាំងអស់ | 3,291,759,000 |
| 1.4.3.2 | សវនកម្មផ្ទៃក្នុងលើការអនុវត្តហិរញ្ញវត្ថុឆ្នាំ២០១៧ ត្រូវបានអនុវត្ត | 190,836,000 |
| | **សរុបរួម** | **22,427,392,750** |

# សមាសភាគទីពីរ ៖ អភិបាលកិច្ចល្អ

## ក. សេចក្តីផ្តើម

ការអនុវត្ត និងការគ្រប់គ្រង ផ.ស.ថ. ឆ្នាំ២០១៨ ត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃស្នូលទាំង៤នៃកំណែទម្រង់វិមជ្ឈការដែលបានកំណត់ក្នុងផអ៣ទី៣ រួមមាន ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធនធានសមស្រប និងភាពជាដៃគូ។ គោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់អភិបាលកិច្ចល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ការលើកកម្ពស់អភិបាលកិច្ចល្អផ្តោតជាសំខាន់លើទំនាក់ទំនងអភិបាលកិច្ចចំនួន៣គឺ ទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយគណៈអភិបាល និងទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយរាជរដ្ឋាភិបាល រួមបញ្ចូលទាំងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងទំនាក់ទំនងទាំង៣នេះ។ ជាមួយគ្នានេះដែរ អភិបាលកិច្ចល្អរួមបញ្ចូលគណនេយ្យភាពនយោបាយ គណនេយ្យភាពសង្គម និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ ជាពិសេស គណនេយ្យភាពតាមបែបប្រជាធិបតេយ្យបង្ហាញឱ្យឃើញតាមរយៈទំនាក់ទំនងអភិបាលកិច្ចរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយគណៈអភិបាលរបស់ខ្លួនដូចជា កិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាក្នុងនាមប្រជាពលរដ្ឋ និងការធានាឱ្យមានគណនេយ្យភាពរបស់មន្ត្រីសាធារណៈក្រុមប្រឹក្សារបស់ខ្លួន។ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ គឺជាសមត្ថកិច្ចដ៏មានមានសារសំខាន់ក្នុងការផ្ទេរមុខងារពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងការលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅ។

## ខ. គោលដៅ និងសមិទ្ធផលរំពឹងទុក

សមាសភាគទីពីរមានគោលដៅ **ពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

សមិទ្ធផលសំខាន់ៗដែលត្រូវសម្រេចបានរួមមាន ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិមានការប្រាស្រ័យទាក់ទង និងឆ្លើយតបចំពោះប្រជាពលរដ្ឋកាន់តែល្អប្រសើរ
- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាតំណាងប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគោលនយោបាយនានា
- រដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាព និងអនុវត្តបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដានានារបស់ថ្នាក់ជាតិដោយផ្សារភ្ជាប់នឹងការវិភាជធនធាន និងការលើក ទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកលើលទ្ធផលការងារ
- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងការងាររបស់ខ្លួនបានល្អប្រសើរ និងមានប្រសិទ្ធភាព

- រដ្ឋបាលថ្នាក់ក្រោមជាតិដោះស្រាយ និងលើកកម្ពស់សុខុមាលភាពរបស់ក្រុមជនងាយរងគ្រោះនានា។

## គ. សូចនាករ និងចំណុចដៅ

សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨មានចំនួន **១៧** ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម។

**តារាងទី៨ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីពីរ**

| ល.រ. | សូចនាករ | ចំណុចដៅ | |
|---|---|---|---|
| | | ដើមគ្រា | ២០១៨ |
| ១. | ផែនការអនុវត្តប្រាំឆ្នាំស្តីពីការងារគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់ | | រៀបចំ |
| ២. | ភាគរយនៃ I4C អំពីការផ្តល់សេវាបានប្រមូល និងបញ្ចូលក្នុងកុំព្យូទ័រ | ៨៧ | ៩៨ |
| ៣. | យន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងបានរៀបចំ និងផ្សព្វផ្សាយ | | រៀបចំ |
| ៤. | ចំនួនបណ្តឹង ត្រូវបានសម្រុះសម្រួលដោះស្រាយ | ៣៧៨ | ៥០០ |
| ៥. | ចំនួនសរុប SNAs បានធ្វើអធិការកិច្ចដោយក្រសួងមហាផ្ទៃ | ០ | ១០ |
| ៦. | ក្របខ័ណ្ឌវាយតម្លៃលទ្ធផលនៃការបំពេញការងាររបស់ SNAs | | រៀបចំ |
| ៧. | ការពិនិត្យមើលឡើងវិញលើប្រព័ន្ធអនុវត្តការងាររបស់ SNAs | | សាកល្បង |
| ៨. | ភាគរយនៃរដ្ឋបាលក្រុង ស្រុកទទួលបាន និងប្រើប្រាស់ប្រព័ន្ធ MIS | | ២០ |
| ៩. | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ SNAs បានកែសម្រួល និងដាក់ឱ្យប្រើប្រាស់ | | វិភាគ |
| ១០. | ប្រព័ន្ធទិន្នន័យមូលដ្ឋានបុគ្គលិកបានរៀបចំ | | វិភាគ |
| ១១. | ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង | | អនុវត្ត |
| ១២. | ភាគរយអភិបាល/អភិបាលរងបានរៀនវគ្គកាតព្វកិច្ចស្តីពីយេនឌ័រ | ៦០ | ៩៥ |
| ១៣. | ភាគរយស្ត្រីកាន់មុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ១២,១ | ២០ |
| ១៤. | ភាគរយស្ត្រីកាន់មុខតំណែងគ្រប់គ្រងថ្នាក់ក្រុង ស្រុក ខណ្ឌ | ២១,៥ | ២៥ |
| ១៥. | កម្មវិធីដែលបានអនុវត្តលើកកម្ពស់យុវជន ជនពិការ ជនជាតិដើមភាគតិច | | រៀបចំ |
| ១៦. | SNA ផ្តល់មូលនិធិគាំទ្រកិច្ចគាំពារសង្គម (គិតជាលានដុល្លារ) | | ១ |
| ១៧. | ក្រសួង ស្ថាប័ន និង SNAs ផ្តល់ថវិកាគាំទ្រគណៈកម្មាធិការ/ក្រុមការងារយេនឌ័រ | | អនុវត្ត |

## ឃ. លទ្ធផលរំពឹងទុក និងថវិកា

សមាសភាគទីពីរមានលទ្ធផលរំពឹងទុកចំនួន១៧ ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៨ ដូចមានរៀបរាប់ក្នុងតារាងទី៩ខាងក្រោម។

ផែនការចំណាយថវិកាសរុបរបស់សមាសភាគនេះមានចំនួន៣៣ពាន់លានរៀល ដែលក្នុងនោះរួមមានថវិកាគាំទ្ររបស់រាជរដ្ឋាភិបាលចំនួន៩ពាន់លានរៀល និងថវិកាគាំទ្ររបស់ដៃគូអភិវឌ្ឍនានាមានចំនួន ២៤ពាន់លានរៀល។

តារាងសមាសភាគ សមិទ្ធផល លទ្ធផលរំពឹងទុក សកម្មភាព និងថវិកាលម្អិតនៃ ផ.ស.ថ. ឆ្នាំ ២០១៨ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី១។

## តារាងទី៩ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីពីរ

| លេខកូដ | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 2.1.1.1 | ការងារគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីកការអនុវត្តក្នុងស្រុកគោលដៅចំនួន៩៨ | 18,910,990,450 |
| 2.1.2.1 | យន្តការដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ | 3,373,368,900 |
